ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១២៤ ស្តីពីការលុបឈ្មោះឯកឧត្តម **ម៉ែន រុន** ឧត្តមមន្ត្រី ថ្នាក់លេខ ៣ និងជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ចេញពីក្របខ័ណ្ឌ មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុ ទទួលមរណភាព ២៩៥២

២៣-០៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១២៥ ស្តីពីការតែងតាំងលោក **សែម ចាន់ដារ៉ុង** ជា ឧកញ៉ា ២៩៥៣

២៣-០៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១២៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ ចំនួន ៣៤ រូប ២៩៥៤

២៣-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១២៧ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **គង សំអឿន** ២៩៥៦

២៣-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១២៨ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកឧត្តមសេនីយ៍ត្រី **ជួន ឃឿន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ២៩៥៧

២៦-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១២៩ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះនាយទាហានជាន់ខ្ពស់ បរទេស ចំនួន ០៣ រូប ២៩៥៨

២៦-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១៣០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម លោកឧកញ៉ា និងអស់លោក ចំនួន ២១១ រូប ២៩៥៨

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ២៩៦៦
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៤
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៥
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៦
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៧
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៨
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៧២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩៨០
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨១
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨២
២៨-៣-២០០៧ -អនុក្រឹត្យលេខ ២៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៤
២៩-៣-២០០៧ -អនុក្រឹត្យលេខ ២៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៥
២៩-៣-២០០៧ -អនុក្រឹត្យលេខ ២៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៦
២៩-៣-២០០៧ -អនុក្រឹត្យលេខ ២៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៧
២៩-៣-២០០៧ -អនុក្រឹត្យលេខ ២៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៨
២៩-៣-២០០៧ -អនុក្រឹត្យលេខ ២៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៩

២.សេចក្តីសំរេច

២៧-៣-២០០៧ -សេចក្តីសំរេចលេខ ១៧ សសរ ស្តីពីការបង្កើតគណៈកម្មការជំនាញសម្រាប់បារាយណ៍ទឹកថ្លា ខេត្តសៀមរាប ២៩៩០

III.ក្រសួងស្ថាប័ន

១.ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-៣-២០០៧ -ប្រកាសលេខ ១៩២ សហវ.ប្រក ស្តីពីការបង្កើត អង្គភាពគ្រប់គ្រងសាច់ប្រាក់ក្រោមឱវាទអគ្គលេខាធិការដ្ឋាន សំរាប់ជាសេនាធិការបច្ចេកទេសអោយ គ.ជ.ស នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២៩៩៣

២.នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជិន សាន់ អ៊ីមផត អិចផត** ២៩៩៥

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមរា ថេកណូឡូជី** ២៩៩៧

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី អ៊ី ខេ(ខេមបូឌា)** ២៩៩៩

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃុសាធីរ៉ា អ៊ិនធើណេសិនណាល** ៣០០១

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អៀវ សុខ ហេង អ៊ីមផត អិចផត** ៣០០៣

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ.អិន.ធី.ម៉ោល ជេន លែន** ៣០០៥

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ដាប់បែលយូ-ខេម អ៊ីឃើណមីក ត្រេដ សេនធ័រ** ៣០០៧

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ក្រោន អេនធើប្រាយ** ៣០០៩

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេបភី ម៉ាឃីត គ្រុប អ៊ីន** ៣០១១

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃែត អ៊ែតទើថាយស៊ីង អេជេនស៊ី** ៣០១៣

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានលុបឈ្មោះឯកឧត្តម ម៉ែន រុន ឧត្តមមន្ត្រី ថ្នាក់លេខ ៣ និងជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ចេញពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុ ទទួលមរណភាព ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣៧.០៧០៣.១៣៤

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧

លេខ ១៤៧ ច.ល
ជម្រាបជូនចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

នស/រកត/០៣០៧/១២៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក សែម ចាន់ដារ៉ុង

ជា

ឧកញ៉ា

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣.ល.០៧០៣.១៣៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រ្តីពិរាស្រ្ត ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ដល់

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

-ឧត្តមសេនីយ៍ទោ ចាប ភក្តី អត្តលេខ ០០០៤៣០

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-ឧត្តមសេនីយ៍ត្រី សុខ្ន សារឿន អត្តលេខ ០០២១២៥

២-ឧត្តមសេនីយ៍ត្រី ម៉ា តិរស្ស អត្តលេខ ០០៣៥០៤

៣-ឧត្តមសេនីយ៍ត្រី មួន សារ៉េត អត្តលេខ ០០០៧៧០

៤-វរសេនីយ៍ឯក សៀង សំអឿន អត្តលេខ ០០៤២១០

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-វរសេនីយ៍ឯក ម៉ៅ សំណាង អត្តលេខ ០០២៤១៨

២-វរសេនីយ៍ឯក ឌុំ សារ៉ាធុន អត្តលេខ ០០៤២១៣

៣-វរសេនីយ៍ទោ យិន ជំនិត អត្តលេខ ០០៤២១១

៤-វរសេនីយ៍ទោ សួស ចំរើន អត្តលេខ ០០៤២១៨

៥-វរសេនីយ៍ទោ យឹម ថុន្នី អត្តលេខ ០០៤២២៤

៦-វរសេនីយ៍ទោ ស៊ុំ សំណាង អត្តលេខ ០០៤៨៦៨

៧-វរសេនីយ៍ទោ រ៉ែម សារ៉េត អត្តលេខ ០០៤៨៦៩

៨-វរសេនីយ៍ទោ សំ សារ៉ាធុន អត្តលេខ ០០៤២១៩

៩-វរសេនីយ៍ទោ ឈួន សារិន អត្តលេខ ០១០៣២១

១០-វរសេនីយ៍ទោ ឌុំ សំអុន អត្តលេខ ០០៤២១៦

១១-វរសេនីយ៍ត្រី ចាប សុធន អត្តលេខ ០១០៣១៩

១២-វរសេនីយ៍ត្រី ចែម សេរីសុភា អត្តលេខ ០២៤៤៥៨
១៣-វរសេនីយ៍ត្រី ម៉េត ឡុក អត្តលេខ ០១៩៤២៩
១៤-វរសេនីយ៍ត្រី យ៉ែម ឫទ្ធី អត្តលេខ ០០៩៤២៩
១៥-វរសេនីយ៍ត្រី ឈា សារឿន អត្តលេខ ០០៤២២១
១៦-វរសេនីយ៍ត្រី ចាប គឹមសាន្ត អត្តលេខ ០១២៣២៤
១៧-វរសេនីយ៍ត្រី រស់ សុខា អត្តលេខ ០១៧៤៥៦
១៨-វរសេនីយ៍ត្រី ម៉ុត សំបូរ អត្តលេខ ០១២៣៣៦
១៩-វរសេនីយ៍ត្រី កែវ សុខា អត្តលេខ ០១០៣២៦
២០-វរសេនីយ៍ត្រី សុខ នូសាន្ត អត្តលេខ ០១២៣៣៣
២១-វរសេនីយ៍ត្រី នុត ចំនូម៉ារ៉ា អត្តលេខ ០១០៣៣០
២២-វរសេនីយ៍ត្រី អុំ ណត់ អត្តលេខ ០១០៣២៧
២៣-វរសេនីយ៍ត្រី ជូ អេង អត្តលេខ ០១២៣៤១
២៤-វរសេនីយ៍ត្រី យ៉េង ស៊ីវន អត្តលេខ ០១២៣៣២
២៥-វរសេនីយ៍ត្រី នឹង ឈាង អត្តលេខ ០០៩៤៥២
២៦-វរសេនីយ៍ត្រី ឃួន អែត អត្តលេខ ០០៩៤៥០
២៧-វរសេនីយ៍ត្រី យឹម សុខា អត្តលេខ ០១២៣២៥
២៨-វរសេនីយ៍ត្រី កែវ សុផល អត្តលេខ ០១០៣២៣
២៩-វរសេនីយ៍ត្រី ព្រឹល សាវី អត្តលេខ ០១៩៣៩៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ន.ស.រ.កត.០៣០៣.១៣៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១៥០ ច.ល
ថតចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនគេន

នស/រកត/០៣០៧/១២៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូន

-លោកវរសេនីយ៍ឯក **កង សំអឿន** អត្តលេខ ០០០៣៦៣

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រហ.០៧០៣.១៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មី.ន ឆ្នាំ២០០៧

លេខ: ១៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន វិនកេន

នស/រកត/០៣០៧/១២៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកឧត្តមសេនីយ៍ត្រី **ជួន ចឿន** អត្តលេខ ០៤៥០ នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៣.១៣៨

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១៨៨ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៧
ទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ិន តេន

នស/រកត/០៣០៧/១២៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ

១-ឯកឧត្ដម ឧត្ដមសេនីយ៍ទោ BAMBANG DARMONO
២-ឯកឧត្ដម ឧត្ដមសេនីយ៍ទោ SUR0YO GINO
៣-ឯកឧត្ដម ឧត្ដមសេនីយ៍ទោ SAFNIL ARMIAN

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ/ល.០៧០៣.១៣៩

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១៤៩ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក ឃុន ទុធ
២-ឯកឧត្តម ឧត្តមសេនីយ៍ទោ ចៅ តុល
៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ ឡៀង សារុន
៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ ហេង សាវឿន
៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ សុខៈ
៦-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ យាន
៧-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ ចារុណ្ណ
៨-ឯកឧត្តម ឧត្តមសេនីយ៍ទោ អ៊ុំ ម៉ារា
៩-ឯកឧត្តម ប៉ែន សំអាត

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ

១-ឯកឧត្តម សុខ ផេង
២-ឯកឧត្តម ឧត្តមនារីឯក អ៊ុង សំខាន់
៣-ឯកឧត្តម ឧត្តមនារីទោ ឡៀ វិញ
៤-ឯកឧត្តម ឧត្តមនារីទោ អ៊ុក សីហា
៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ ហួត ឈាង
៦-ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៊ិច សូឌី
៧-ឯកឧត្តម ឧត្តមសេនីយ៍ទោ អ៊ុង សារិទ្ធ
៨-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ សុវណ្ណា
៩-ឯកឧត្តម ឧត្តមសេនីយ៍ទោ នួន ណារិន្ទ
១០-ឯកឧត្តម ឧត្តមសេនីយ៍ទោ យិន សុខា

១១-ឯកឧត្តម ឧត្តមសេនីយ៍ទោ	អ៊ុក កោសា
១២-ឯកឧត្តម ឧត្តមសេនីយ៍ទោ	សោម ជន
១៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ	ទៀង ឫទ្ធី
១៤-ឯកឧត្តម	ឆេង សារឿន
១៥-ឯកឧត្តម	ឡូយ សុផាត
១៦-ឯកឧត្តម	ទ៉ា ឈុជា
១៧-ឯកឧត្តម	សួស យ៉ារ៉ា
១៨-ឯកឧត្តម	ជា ទ៉ាន់ដេត
១៩-ឯកឧត្តម	ស៊ិន សុខណា
២០-ឯកឧត្តម	ស៊ី ហ៊ូហ៊ុយ
២១- ឯកឧត្តម	អ៊ុំ ឆាយ
២២-ឧកញ៉ា	រ៉ាន ម៉ាឌី
២៣-ឧកញ៉ា	ដួង ហេង
២៤-ឧកញ៉ា	ឌី ប៊ូ
២៥-ឯកឧត្តម ឧត្តមសេនីយ៍ត្រី	គោគ ចន្ថា
២៦-ឯកឧត្តម ឧត្តមសេនីយ៍ត្រី	យី ភុយ
២៧-លោកឧត្តមសេនីយ៍ត្រី	នាម អឿង
២៨-លោកឧត្តមសេនីយ៍ត្រី	ហេង ឫទ្ធី
២៩-លោកឧត្តមសេនីយ៍ត្រី	យង់ សារិទ្ធ
៣០-លោកឧត្តមសេនីយ៍ត្រី	នៅ សាទ៊ន
៣១-លោកឧត្តមសេនីយ៍ត្រី	ស៊ឹម សុទ្ធ
៣២-លោកឧត្តមសេនីយ៍ត្រី	គន់ ហេង
៣៣-លោកឧត្តមសេនីយ៍ត្រី	ណុប រតនា
៣៤-លោកឧត្តមសេនីយ៍ត្រី	លន់ សុធី
៣៥-លោកឧត្តមសេនីយ៍ត្រី	អ៊ុក សុទ្ធសេន
៣៦- លោកឧត្តមសេនីយ៍ត្រី	យ៉េប ភុយ
៣៧- លោកវរសេនីយ៍ឯក	ទៀប ហ៊ិន
៣៨-លោក	ឃី ចណ្ណវិសាល
៣៩-លោក	សេង សត្ថា

គ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ

១-ឯកឧត្តម	អ៊ុក ដាម៉ារី
២-ឯកឧត្តម	ឡាយ សុខា
៣-ឯកឧត្តម	មួង ប៉ិយ
៤-ឯកឧត្តម	គឹម គុណវឌ្ឍន៍
៥-ឯកឧត្តម	ឌួង អេលីត
៦-ឯកឧត្តម	ថៃ នរៈសត្យា
៧-ឯកឧត្តម	ម៉ោញ សំអាត

ROYAUME DU CAMBODGE … MINISTÈRE DU PALAIS ROYAL

៨-ឯកឧត្តម	ពេជ គៅ
៩-ឯកឧត្តម ឧត្តមសេនីយ៍ទោ	លី កុសល
១០-ឯកឧត្តម ឧត្តមសេនីយ៍ទោ	ច្រាក់ ផល្លី
១១-លោកឧត្តមសេនីយ៍ត្រី	ទី សំណាង
១២-លោកឧត្តមសេនីយ៍ត្រី	កែវ សុខគី
១៣-លោកឧត្តមសេនីយ៍ត្រី	យ៉ាត រិទ្ធ
១៤-លោកឧត្តមសេនីយ៍ត្រី	វង្ស វង
១៥-លោកឧត្តមសេនីយ៍ត្រី	ថាន់ សារី
១៦-លោកឧត្តមសេនីយ៍ត្រី	ចាន់ ប៊ុណ្ណ
១៧-លោកឧត្តមសេនីយ៍ត្រី	សួន ខំឡ
១៨-លោកឧត្តមសេនីយ៍ត្រី	អន សារិទ្ធ
១៩-លោកឧត្តមសេនីយ៍ត្រី	ហេង ខាំវណ្ណ
២០-លោកឧត្តមសេនីយ៍ត្រី	ខាំ ផាយ
២១-លោកឧត្តមសេនីយ៍ត្រី	ស្រ៊ុន សារឿន
២២-លោកឧត្តមសេនីយ៍ត្រី	សូ សារឿន
២៣-លោកឧត្តមសេនីយ៍ត្រី	ព្រហ្ម ពន្លឺ
២៤-លោកឧត្តមសេនីយ៍ត្រី	លឹម ឡេង
២៥-លោកឧត្តមសេនីយ៍ត្រី	ម៊ូ សារ៉េន
២៦-លោកឧត្តមសេនីយ៍ត្រី	អ៊ុន សារិន
២៧-លោកឧត្តមសេនីយ៍ត្រី	ម៉ៃ សារឿន
២៨-លោកវរសេនីយ៍ឯក	ម៉ិល យុវឌ្ឍនា
២៩- លោកវរសេនីយ៍ឯក	ម៉េន សារ៉ាត់
៣០-លោកវរសេនីយ៍ឯក	សុខ សារ
៣១-លោកវរសេនីយ៍ឯក	ឌួន គឿន
៣២-លោកវរសេនីយ៍ឯក	ស៊ឹម ហុង
៣៣-លោកវរសេនីយ៍ឯក	នន្ទ និន
៣៤-លោកវរសេនីយ៍ឯក	អ៊ឹម វណ្ណនេង
៣៥-លោកវរសេនីយ៍ទោ	សុខ វណ្ណា
៣៦-លោកវរសេនីយ៍ទោ	គន់ សុភា
៣៧-ឧកញ៉ា	លាង ឃុន
៣៨-ឧកញ៉ា	ប៊ូ គីមថេង
៣៩-លោក	ហោក សុធារិន
៤០-លោក	ឃ្លាំង ហួត
៤១-លោក	ភាំង អេងឆាយ
៤២-លោក	លាង ម៉េង

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ

១-ឯកឧត្តម	សួង ម៉េងគា

ROYAUME DU CAMBODGE

២-ឯកឧត្តម	ឈាល់ ច័ន្ទតារា
៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ	ម៉ៅ ញ៉ី
៤-លោកឧត្តមសេនីយ៍ត្រី	សុខ វណ្ណារ៉ា
៥-លោកឧត្តមសេនីយ៍ត្រី	លឹម សុធា
៦-លោកឧត្តមសេនីយ៍ត្រី	សួន ពិរុណ
៧-លោកឧត្តមសេនីយ៍ត្រី	ទូន សុខូ
៨-លោកឧត្តមសេនីយ៍ត្រី	ឌុន សុខុន
៩-លោកឧត្តមសេនីយ៍ត្រី	កើត វន
១០-លោកឧត្តមសេនីយ៍ត្រី	សួស ស៊ីណា
១១-លោកឧត្តមសេនីយ៍ត្រី	នៅ សារ៉ុន
១២-លោកឧត្តមសេនីយ៍ត្រី	យ៉ាត ទូច
១៣-លោកឧត្តមសេនីយ៍ត្រី	ប្រាជ្ញ សុផល
១៤-លោកឧត្តមសេនីយ៍ត្រី	ឈឹម វាសនា
១៥-លោកឧត្តមសេនីយ៍ត្រី	យូ សារ៉ាន់
១៦-លោកវរសេនីយ៍ឯក	នយ មុត
១៧-លោកវរសេនីយ៍ឯក	សេង ម៉ុនហេង
១៨-លោកវរសេនីយ៍ឯក	អ៊ុក ឃួច
១៩-លោកវរសេនីយ៍ឯក	ឌុយ កើន
២០-លោកវរសេនីយ៍ឯក	ហ៊ូ ហៀង
២១-លោកវរសេនីយ៍ឯក	ស៊ូ សម្បត្តិ
២២-លោកវរសេនីយ៍ឯក	ម៉ែន មាស
២៣-លោកវរសេនីយ៍ឯក	តេង សួន
២៤-លោកវរសេនីយ៍ឯក	អ៊ុង សិរីគន្ធ
២៥-លោកវរសេនីយ៍ឯក	ទូន ហុង
២៦-លោកវរសេនីយ៍ឯក	នូ ប្រុសពៅ
២៧-លោកវរសេនីយ៍ឯក	សុខ គីមអេង
២៨-លោកវរសេនីយ៍ឯក	ឡោ ផុន
២៩-លោកវរសេនីយ៍ឯក	ញឹក ផុន
៣០-លោកវរសេនីយ៍ឯក	សុខ សំអុល
៣១-លោកវរសេនិយ៍ឯក	ម៉ុញ ពិសិដ្ឋ
៣២-លោកវរសេនីយ៍ឯក	ម៉ុន ឆាយ
៣៣-លោកវរសេនីយ៍ឯក	ស៊ុន ហួរ
៣៤-លោកវរសេនយ៍ឯក	ព្រាប លីណា
៣៥-លោកវរសេនីយ៍ឯក	ឯល វណ្ណថន
៣៦-លោកវរសេនីយ៍ឯក	ស្រួល សុជា
៣៧-លោកវរសេនីយ៍ឯក	ម៉ើន សុខ
៣៨-លោកវរសេនីយ៍ឯក	ឡេង ម៉ុនណា

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

៣៩-លោកវរសេនីយ៍ឯក	ជែត សារ៉ុន
៤០-លោកវរសេនីយ៍ឯក	មាស នារ៉ាំ
៤១-លោកវរសេនីយ៍ឯក	ខាំ ស៊ុក
៤២-លោកវរសេនីយ៍ឯក	ហែម ថេង
៤៣-លោកវរសេនីយ៍ឯក	ម៉ុំ សំ
៤៤-លោកវរសេនីយ៍ឯក	ញ៉ៀម សុខន្ធី
៤៥-លោកវរសេនីយ៍ទោ	យង់ ម៉ុនថាត
៤៦-លោកវរសេនីយ៍ទោ	ម៉ម តុលា
៤៧-លោកវរសេនយ៍ទោ	គីម តិច
៤៨-លោកវរសេនីយ៍ទោ	គីម ពៅ
៤៩-លោកវរសេនីយ៍ទោ	គង់ ដារ៉ារិទ្ធ
៥០-លោកវរសេនីយ៍ទោ	កែវ នាង
៥១-លោកវរសេនីយ៍ទោ	ខៀវ រិទ្ធី
៥២-លោកវរសេនីយ៍ទោ	គង់ ភក្តារិទ្ធ
៥៣-លោកវរសេនីយ៍ត្រី	ធីវ មុល
៥៤-លោកវរសេនីយ៍ត្រី	ខាំ ធិម
៥៥-លោកវរសេនីយ៍ត្រី	ឡេង ជន់
៥៦-លោកអនុសេនីយ៍ឯក	ម៉ី ម៉ុនម៉ន
៥៧-លោកអនុសេនីយ៍ឯក	សំ គីមស្រ៊ី
៥៨-លោក	អោក ចន
៥៩-លោក	អ៊ុយ សារិន
៦០-លោក	ឆិត ដា
៦១-លោក	គីម សឡាត

ខ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ

១-ឯកឧត្តម	ចាយ ប៊ូរិន្ទ
២-លោកវរសេនីយ៍ត្រី	គង់ ច័ន្ទ
៣-លោកវរសេនីយ៍ឯក	គង់ ចាន់ថន
៤-លោកវរសេនីយ៍ឯក	ហួត សាឃាន
៥-លោកវរសេនីយ៍ឯក	អន ណារ៉ាត្រី
៦-លោកវរសេនីយ៍ឯក	ធឹង យារ៉ា
៧-លោកវរសេនីយ៍ឯក	ប៊ីក ភាន
៨-លោកវរសេនីយ៍ឯក	សរ សារ៉ែន
៩-លោកវរសេនីយ៍ឯក	ហ៊ួន ម៉ុនធឿន
១០-លោកវរសេនិយ៍ឯក	លឹម ចាន់ថុល
១១-លោកវរសេនីយ៍ឯក	សំ សំអុល
១២-លោកវរសេនីយ៍ឯក	លៀង សារុន
១៣-លោកវរសេនីយ៍ឯក	នួច ឌំល្អា

ROYAUME DU CAMBODGE MINISTERE du PALAIS ROYAL

១៤-លោកវរសេនីយ៍ឯក	ឃ្លោក មើន
១៥-លោកវរសេនីយ៍ឯក	ឡាំ ម៉ុនលុច
១៦-លោកវរសេនីយ៍ឯក	ម៉ាច ចាន់ថុល
១៧-លោកវរសេនីយ៍ឯក	ម៉ា ថន
១៨-លោកវរសេនីយ៍ឯក	នុត ម៉ុនថុល
១៩-លោកវរសេនីយ៍ឯក	ចាន់ ណារិទ្ធ
២០-លោកវរសេនីយ៍ឯក	យូ ឈុនលី
២១-លោកវរសេនីយ៍ឯក	ផាត់ តា
២២-លោកវរសេនីយ៍ឯក	កែវ សុផល
២៣-លោកវរសេនីយ៍ឯក	ស៊ិន សារ៉ែត
២៤- លោកវរសេនីយ៍ឯក	នៅ សារិទ្ធ
២៥- លោកវរសេនីយ៍ឯក	សាយ សាគង់
២៦- លោកវរសេនីយ៍ឯក	ហែម សារ៉ាន់
២៧- លោកវរសេនីយ៍ឯក	វង្ស សុភ័ក្ត្រ
២៨- លោកវរសេនីយ៍ឯក	លិន សុផល
២៩- លោកវរសេនីយ៍ឯក	ជៀម ឡាក់
៣០- លោកវរសេនីយ៍ឯក	ចាន់ លី
៣១- លោកវរសេនីយ៍ឯក	ឡាក់ សាវុធ
៣២-លោកវរសេនីយ៍ឯក	ឡាយ លីមស្រួយ
៣៣-លោកវរសេនីយ៍ទោ	សេង ឌីលីន
៣៤-លោកវរសេនីយ៍ទោ	ទឹម សំអួន
៣៥-លោកវរសេនីយ៍ទោ	ជា សារឿន
៣៦-លោកវរសេនីយ៍ទោ	អ៊ុក ឆូ
៣៧-លោកវរសេនីយ៍ទោ	សរ បូរ៉ា
៣៨-លោកវរសេនីយ៍ទោ	សេង ឌីលីន
៣៩-លោកវរសេនីយ៍ទោ	ឡុង សាវឿន
៤០-លោកវរសេនីយ៍ទោ	ម៉ាន គីមស្រួន
៤១-លោកវរសេនីយ៍ទោ	តោគ សម្បត្តិ
៤២-លោកវរសេនីយ៍ទោ	នួន នឿន
៤៣-លោកវរសេនីយ៍ទោ	ជីវ យឹម
៤៤-លោកវរសេនីយ៍ទោ	ខួន តារ៉ាវុធ
៤៥-លោកវរសេនីយ៍ទោ	មិន សាម៉េត
៤៦-លោកវរសេនីយ៍ទោ	ញៀម សឿន
៤៧-លោកវរសេនីយ៍ទោ	ឡៅ ម៉ុនម៉េង
៤៨-លោកវរសេនីយ៍ទោ	សួន ពឿន
៤៩-លោកវរសេនីយ៍ទោ	ជា ម៉ើម
៥០-លោកវរសេនីយ៍ទោ	ម៉ៅ ពៅ

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

៥១- លោកវរសេនីយ៍ទោ	ភៅ តេនា
៥២-លោកវរសេនីយ៍ត្រី	អ៊ុំ តូច
៥៣-លោកវរសេនីយ៍ត្រី	ឃឿន គីមឃុន
៥៤-លោកវរសេនីយ៍ត្រី	ទ្រី ម៉ុង
៥៥-លោកស្រី	ទេព សុទ្ធី
៥៦-លោក	ស្វាយ ដួត
៥៧-លោក	ឡុង ផលគុណ
៥៨-លោក	ឈៅ សួន
៥៩-លោកវរសេនីយ៍ត្រី	ហែម ឡុងតង់
៦០-លោកវរសេនីយ៍ត្រី	ឡុង វិសិដ្ឋ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ល.០៧០៣.១៤០

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១៤៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៣០៥/ ០០៥ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៥ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើត អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះកំណត់អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម (អ.ជ.អ.គ) ។

ជំពូកទី ២
តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

មាត្រា ២.-

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ.មានតួនាទី និងភារកិច្ចដូចតទៅ ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពក្នុងការគ្រប់គ្រង ទប់ស្កាត់ការរីកសាយ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម និងសារធាតុផ្សំដែលទាក់ទងនឹងការផលិតអាវុធគីមី ដើម្បីដាក់ជូន អ.ជ.អ.គ.
- អនុវត្តគោលនយោបាយ សារាចរ សេចក្តីណែនាំ បទបញ្ជា របស់អ.ជ.អ.គ និងរាជរដ្ឋាភិបាល
- អនុវត្តរាល់ខ្លឹមសារនៃសន្ធិសញ្ញា អនុសញ្ញា និងស្វែងយល់រាល់ការអនុវត្តរបស់អាជ្ញាធរជាតិនៃបណ្តាប្រទេសនានា ដែលជារដ្ឋភាគី
- ផ្សព្វផ្សាយ អប់រំ ធានាការអនុវត្ត និងតាមដាន ត្រួតពិនិត្យ រាល់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលរាជរដ្ឋាភិបាលបានសម្រេច
- រៀបចំលិខិតបទដ្ឋាននានា ទាក់ទងនឹងរាល់កិច្ចប្រជុំ ការចរចា ការចុះហត្ថលេខាលើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង អនុស្សរណៈ ពិធីសារ កិច្ចសន្យា និងគម្រោងជំនួយទ្វេភាគី ពហុភាគី ដែលពាក់ព័ន្ធនឹងអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដើម្បីដាក់ជូន អ.ជ.អ.គ.
- ចាត់ចែងការងារឱ្យស្របទៅតាមវិធានការនានា ដែល អ.ជ.អ.គ. បានសម្រេចដើម្បី

គ្រប់គ្រង ត្រួតពិនិត្យ ទប់ស្កាត់ ចេញកំណត់ការនាំចេញ នាំចូល ការឆ្លងកាត់ ការស្តុកទុកសារធាតុគីមី និងជីវសាស្ត្រ និងសារធាតុទាក់ទងនឹងនុយក្លេអ៊ែរ និងវិទ្យុសកម្ម

- ប្រមូលពត៌មាន តាមដាន និងត្រួតពិនិត្យការងារនៃការទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម
- បូកសរុបលទ្ធផលនៃការនាំចេញ នាំចូល នូវរាល់សារធាតុគីមី ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- កៀរគរប្រភពធនធាន ជំនួយបច្ចេកទេស អាហារូបករណ៍ និងហិរញ្ញវត្ថុ ក្នុង និងក្រៅប្រទេស
- គ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងភស្តុភាររបស់ អ.ជ.អ.គ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល អ.ជ.អ.គ ប្រគល់ជូន ។

មាត្រា ៣.-

អគ្គលេខាធិការ មានតួនាទី និងភារកិច្ចដូចតទៅ :-

- គ្រប់គ្រង ចាត់ចែង និងដឹកនាំការងារប្រចាំថ្ងៃ របស់អគ្គលេខាធិការដ្ឋាន នៃ អ.ជ.អ.គ.
- សម្របសម្រួលរាល់ការងារជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិនានា
- រៀបចំកិច្ចប្រជុំរបស់ អ.ជ.អ.គ. និងកិច្ចប្រជុំនានា
- ត្រួតពិនិត្យ និងផ្តល់ការណែនាំក្នុងការប្រើប្រាស់ថវិកា និងសម្ភារៈ បរិក្ខារដែលផ្តល់ដោយរាជរដ្ឋាភិបាល និងជំនួយរបស់សហគមន៍ជាតិ និងអន្តរជាតិ ដល់សកម្មភាពទប់ស្កាត់ការរីកសាយអាវុធគីមី និងសារធាតុគីមី
- ស្នើសុំជ្រើសរើស តែងតាំង ឬដកចេញពីតំណែង នូវមន្ត្រី បុគ្គលិក របស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន អ.ជ.អ.គ. ប្រគល់ជូន ។

មាត្រា ៤.-

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ត្រូវធ្វើការប្រជុំការងារយ៉ាងតិចពីរដងក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

មាត្រា ៥.-

អគ្គលេខាធិការជាអាណាប័កផ្ទេរសិទ្ធិពីប្រធាន អ.ជ.អ.គ ដែលជាអាណាប័កដើមវិញ ។

មាត្រា ៦.-

អគ្គលេខាធិការដ្ឋាន មានមន្ត្រីបំរើការងារមកពីក្របខណ្ឌកងយោធពលខេមរភូមិន្ទ ឬមន្ត្រីក្របខណ្ឌនៃមុខងារសាធារណៈ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋានអាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

មាត្រា ៧.-

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន។

មាត្រា ៨.-

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ មាននាយកដ្ឋាន និងវិទ្យាស្ថានចំណុះដូចតទៅ ÷

- នាយកដ្ឋាន រដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និង ភស្តុភារ
- នាយកដ្ឋាន គ្រប់គ្រងសារធាតុអាវុធគីមី
- នាយកដ្ឋាន ព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍
- នាយកដ្ឋាន ហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញ
- វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៩.-

នាយកដ្ឋាន រដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងភស្តុភារ មានភារកិច្ចដូចតទៅ -

- សម្របសម្រួលផ្នែករដ្ឋបាលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំ និងគ្រប់គ្រងលិខិតបទដ្ឋាន ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ និងអគ្គលេខាធិការដ្ឋាន
- លើកសំណើគម្រោងផែនការរបស់នាយកដ្ឋានជំនាញនានាដាក់ជូនអគ្គលេខាធិការពិនិត្យ និងសម្រេច
- ទទួលរបាយការណ៍ពីនាយកដ្ឋានជំនាញ ដើម្បីបូកសរុប ដាក់ជូនអគ្គលេខាធិការពិនិត្យ
- ត្រួតពិនិត្យ និងបូកសរុបស្ថិតិបុគ្គលិក មន្ត្រីរាជការទូទាំង អគ្គលេខាធិការដ្ឋាន
- រៀបចំសំណុំលិខិតជ្រើសរើស តែងតាំង ឬដកចេញពីតំណែង នូវមន្ត្រី បុគ្គលិក របស់អគ្គលេខាធិការដ្ឋាន នៃ អ.ជ.អ.គ ដើម្បីជូនថ្នាក់លើសម្រេច
- រៀបចំសំណុំលិខិត ជូនរង្វាន់សរសើរ លិខិតសរសើរ ប័ណ្ណសរសើរ គ្រឿងឥស្សរិយយស

គោរម្យងារ ទៅតាមស្នាដៃបុគ្គលិក មន្ត្រីរាជការ និងស្ថាប័នចំណុះអគ្គលេខាធិការដ្ឋាន

- រៀបចំគម្រោងថវិកា ទិសដៅការងារសំរាប់អនុវត្តបន្ត និងសហការជាមួយនាយកដ្ឋានជំនាញដទៃទៀត ដើម្បីលើកគម្រោងសម្ភារៈ បរិក្ខារសំរាប់បំរើការនៅក្នុង អគ្គលេខាធិការដ្ឋាន
- ផ្តល់ការគាំទ្រផ្នែកភស្តុភារដល់អគ្គលេខាធិការដ្ឋាន
- រៀបចំ និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការ នៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃអ.ជ.អ.គ ប្រគល់ជូន។

មាត្រា ១០.-

នាយកដ្ឋាន គ្រប់គ្រងសារធាតុអាវុធគីមី មានភារកិច្ចដូចតទៅ -

- អនុវត្តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីបង្កើតការគ្រប់គ្រងក្នុងប្រទេស ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- សហការ ជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ អង្គភាពរដ្ឋ និងគ្រឹះស្ថាននានា ចាត់វិធានការដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងទប់ស្កាត់ ការចរាចរ នាំចេញ នាំចូល នូវសារធាតុ សំរាប់ផលិតអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ស្រាវជ្រាវ រុករកនូវសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម នៅក្នុងភូមិសាស្ត្រប្រជាពលរដ្ឋ និងក្នុងកងកម្លាំងប្រដាប់អាវុធ
- ធ្វើផែនការ និងលើកគម្រោងទុកជាមុន ស្តីពីសកម្មភាពជួយសង្គ្រោះ និងបន្សាបជាតិពុលដែលបណ្តាលមកអំពីសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ក្នុងករណីកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃ អ.ជ.អ.គ ប្រគល់ជូន។

មាត្រា ១១.-

នាយកដ្ឋាន ព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍ មានភារកិច្ចដូចតទៅ -

- ស្រាវជ្រាវព័ត៌មាន ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ ការធ្វើចរាចរសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

- ផ្សព្វផ្សាយ ធានាការអនុវត្ត ក្នុងការទប់ស្កាត់អោយបានទាន់ពេលវេលា នូវហេតុការណ៍ចៃដន្យ ដែលកើតមានឡើងដោយការរីកសាយអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- សហការជាមួយក្រសួង ស្ថាប័ននានា ដើម្បីប្រមូលព័ត៌មានស្តីពីការទប់ស្កាត់អាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- គ្រប់គ្រង ថែរក្សា និងត្រួតពិនិត្យ សំភារៈ បច្ចេកទេស និងឧបករណ៍ ដែលបានបំពាក់នៅតាមបណ្តាស្ថានីយ៍ត្រួតពិនិត្យទាំងអស់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃ អ.ជ.អ.គ ប្រគល់ជូន។

មាត្រា ១២.-

នាយកដ្ឋាន ហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញ មានភារកិច្ចដូចតទៅ ÷

- ធ្វើផែនការហ្វឹកហ្វឺនមុខជំនាញឯកទេស ស្តីពីបច្ចេកទេសការពារ សង្គ្រោះ ដែលបណ្តាលមកពីអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ធ្វើផែនការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបង្កើនសមត្ថភាពឯកទេសជំនាញ
- រៀបចំគំរោង បើកវគ្គសិក្សា វគ្គបំប៉ន វគ្គបណ្តុះបណ្តាល រយៈពេលខ្លី រយៈពេលវែង និងលើកគម្រោងស្នើសុំអាហារូបករណ៍ ទៅសិក្សានៅក្នុង និងក្រៅប្រទេស
- លើកកំពស់ការយល់ដឹង ដើម្បីស្វែងយល់ពីលក្ខណៈសង្គ្រាមអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ស្រាវជ្រាវ ចងក្រងឯកសារ បោះពុម្ព និងផ្សព្វផ្សាយ សំរាប់ធ្វើការទប់ស្កាត់ការរីករាលដាលអាវុធមហាប្រល័យ ដើម្បីធ្វើការហ្វឹកហ្វឺន
- លើកឡើងពីបទពិសោធន៍ ពាក់ព័ន្ធដល់ការសិក្សា អប់រំ និងការអនុវត្តការងារហ្វឹកហ្វឺនជំនាញឯកទេសអំពីអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃ អ.ជ.អ.គ ប្រគល់ជូន។

មាត្រា ១៣.-

វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី មានភារកិច្ចដូចតទៅ ÷

- ធ្វើការវិភាគ វាយតម្លៃ សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម

- សហការរុករកសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ជាមួយនឹងមន្ទីរពិសោធន៍ក្នុង និងក្រៅប្រទេស
- គ្រប់គ្រងបណ្តុំសម្ភារៈ និងឧបករណ៍ ដែលបានបំពាក់នៅមន្ទីរពិសោធន៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ប្រគល់ជូន ។

មាត្រា ១៤.-

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់ ។

រចនាសម្ព័ន្ធ នៃនាយកដ្ឋាននីមួយៗ និងវិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី របស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ត្រូវកំណត់ដោយប្រកាសរបស់ អ.ជ.អ.គ ។

ជំពូកទី ៣

អវសានប្បញ្ញត្តិ

មាត្រា ១៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិអាវុធគីមី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១៦
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០៧
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

អង្គការលេខ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

អគ្គលេខាធិការដ្ឋាន

- នាយកដ្ឋាន គ្រប់គ្រងសារធាតុអាវុធគីមី
- នាយកដ្ឋាន ព័ត៌មាន និង គ្រប់គ្រងស្ថានីយ៍
- នាយកដ្ឋាន រដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងគណនេយ្យ
- នាយកដ្ឋាន ហ្វឹកហ្វឺន និង បណ្តុះបណ្តាលជំនាញ
- វិទ្យាស្ថាន ស្រាវជ្រាវ និង ពិសោធន៍សារធាតុអាវុធគីមី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦៧ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ខៀវ សែម** សប្បុរសជននៅ ខេត្តកណ្ដាល ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន អស់ចំនួន ២៥.០០០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង រួមជាមួយអណ្ដូងទឹក និងបង្គន់អនាម័យ នៅសាលាឧបសម្ព័ន្ធកន្ទោក ក្នុងឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៦៨ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ
៣៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក WATANABE MIKI អគ្គនាយកអង្គការ **School Aid Japan** ដែលបានឧបត្ថម្ភថវិកា ចំនួន ២២.៦៦៣ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៣ បន្ទប់ អណ្ដូងទឹក ០១ និង បង្គន់អនាម័យ ចំនួន០២ នៅសាលាបឋមសិក្សាភ្នំបំណាក់ ស្ថិតក្នុងភូមិបំណាក់ ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិសាត់ ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤២៧ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ
៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧04/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥. ស្ដីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **KATO OSAMU** សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា តាមរយៈអង្គការ **School Aid Japan** មានទឹកប្រាក់ចំនួន ៣០.៥០៦ ដុល្លារ សំរាប់សាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៥ បន្ទប់ នៅអនុវិទ្យាល័យ ១០ មករា ក្នុងភូមិត្រពាំងកន្ទួត ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិសាត់ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧០ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនកូរ៉េ ចំនួន០៨រូប ដែលបានផ្តល់ថវិកា ដើម្បីជួយសាងសង់ វិហារ គ្រិស្ត សាលារៀន និងមណ្ឌលសុខភាពក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-Mr. KIM HAI JOON	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣០០.០០០ ដុល្លារ
២-Miss. YOUN HWAN KIM	សប្បុរសជននៅប្រទេសកូរ៉េ	ថវិកាចំនួន ៥០.០០០ ដុល្លារ
៣-Mr. LEE HONG KIL	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៥.០០០ ដុល្លារ
៤-Mr. KIM JUN SOO	សប្បុរសជននៅប្រទេសកូរ៉េ	ថវិកាចំនួន ១៥.០០០ ដុល្លារ
៥-Miss. KO EUN YOUNG	សប្បុរសជននៅប្រទេសកូរ៉េ	ថវិកាចំនួន ១៥.០០០ ដុល្លារ
៦-Miss. LEE KIL YA	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៥.០០០ ដុល្លារ
៧-Mr. KWAN HO JUNG	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៥.០០០ ដុល្លារ
៨-Miss. HWI YOUNG JIN	សប្បុរសជននៅប្រទេសកូរ៉េ	ថវិកាចំនួន ១៥.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន២៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ នៅវត្តជ័យឧត្តម ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-លោកព្រឹទ្ធាចារ្យ	**កេតុ កេត្យត្រ**	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន១០.៩៥០ ដុល្លារ
២-លោក	**ខៀវ ឆាច**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន១០.១០០ ដុល្លារ
៣-លោកស្រី	**ដួង ទំ**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន១០.១០០ ដុល្លារ
៤-ឧបាសិកា	**តាន់ អ៊ិន**	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន១០.៣៥០ ដុល្លារ
៥-លោក	**ឈុក សារុន**	សប្បុរសជនខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន ១០.១៥២ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ស្រ៊ិម សារមត**	ចៅអធិការវត្តជ័យឧត្តម	បច្ច័យចំនួន ៥.៣១០ ដុល្លារ
២-លោក	**ឈឹម សារិន**	សប្បុរសជនខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន ៨.០០០ ដុល្លារ
៣-លោក	**នោ ទួន**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៨.១៥០ ដុល្លារ
៤-លោក	**យិន ណាន់**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.១៥៥ ដុល្លារ
៥-ឯកឧត្តម	**ចាក់ សារុង**	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន ៥.១២៦ ដុល្លារ
៦-លោក	**ជួន សៅឌី**	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន ៥.១១០ ដុល្លារ

គ_មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោកស្រី	**នោ សារីន**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៧០០ ដុល្លារ
២-លោក	**ខឹន ខិម**	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកាចំនួន ២.១៥០ ដុល្លារ
៣-ឧបាសិកា	**ធំត្រ រ៉ុក**	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ២.៩៨០ ដុល្លារ

៤-លោក	ចាន់ ផល់	សប្បុរសជនខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន ២.០០០ ដុល្លារ
៥-ឧបាសិកា	ឃ្លិញ ទី	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.៨០៦ ដុល្លារ
៦-លោក	ប្រយុទ្ធកោវិទ្ធភាណុន	សប្បុរសជននៅប្រទេសថៃ	ថវិកាចំនួន ១.៨០០ ដុល្លារ
៧-ឧបាសក	លុក ជួប	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.៥០០ ដុល្លារ
៨-លោក	ធួន រ៉ាឌុធ	សប្បុរសជននៅខេត្តបាត់ដំបង	ថវិកាចំនួន១.៣០០ ដុល្លារ
៩-ឧបាសិកា	ខន ម៉ាលី	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.២៥០ ដុល្លារ
១០-លោក	ចិ ហាច	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន១.២២៥ ដុល្លារ
១១-ឧបាសក	ជួន ប៊ុនរ៉ុក	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.២៥០ ដុល្លារ
១២-លោក	សៀ៊ុខ ឡុន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.១៣០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

ដោយ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រី **Eleanor** Briggs ម្ចាស់មូលនិធិសត្វព្រៃរៀលអន្តរជាតិ ដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយដល់គំរោងអភិរក្សសត្វព្រៃ នៅព្រះរាជាណាចក្រកម្ពុជា សម្រេចបានលទ្ធផលល្អប្រសើរ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៥៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសាលាពុទ្ធិកៈ ០១ខ្នង កុដិ០៣ខ្នង ជណ្តើរ និងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តភ្នំជញ្ជាំង ឃុំទឹកថ្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឧបាសក **មិន ស្រ៊ី** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១២.៥០០ ដុល្លារ

២-ឧបាសិកា **ឈាន អ៊ុច** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-ឧបាសិកា **លី យ៉េកជូ** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ៦.៦០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក **ចយ ថ៊ាត** និងលោកស្រី **សាយ ផារី** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២.៥០០ ដុល្លារ

២-លោក **ឯម ឃុន** និងលោកស្រី **ជែម គីមឈាន** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២.៥០០ ដុល្លារ

៣-លោក **គុយ ហាន់** និងលោកស្រី **ខ៊ាន់ ផល្លា** សប្បុរសជននៅទីក្រុងភ្នំពេញ ថវិកាចំនួន ២.៥០០ ដុល្លារ

៤-ឧបាសិកា **ឃីន ឈោម** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២.៥០០ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ ព្រះពុទ្ធរូប ទូកង ផ្ទាំងគំនូរ ចេតិយ ភ្លេងពិណពាទ្យ ដងទង់ បល្ល័ង្កព្រះ និងចាក់ដីបំពេញទីធ្លា នៅវត្តក្សេត្រីក្តុល ហៅវត្តក្តុល ឃុំក្តុលតាហែន ស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឯកឧត្តម **ឈាំ ឌុំ**	អភិបាលខេត្តកំពង់ធំ	ថវិកាចំនួន ១៨.១១១ ដុល្លារ
២-ឧបាសក **ឌារ សៀកហៃ**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២០.៦៨៨ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-លោក **វ៉ុង សន**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.៣៨៣ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-ឧបាសិកា **ខេន រ៉ុំ**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.០២០ ដុល្លារ
២ -លោក **ជា ជា**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៧៣០ ដុល្លារ
៣ -លោក **ញ៉ឹម ហេង**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.១០០ ដុល្លារ
៤ -លោក **ដែន គាន**	សប្បុរសជនរនៅខេត្តបាត់ដំបង	ថវិកាចំនួន ១.៦៣០ ដុល្លារ
៥ -លោក **កែវ ពិសិដ្ឋ**	សប្បុរសជន នៅខេត្តបាត់ដំបង	ថវិកាចំនួន ១.៥០០ ដុល្លារ
៦ -លោក **គង់ នោមសេរី**	សប្បុរសជន នៅខេត្តបាត់ដំបង	ថវិកាចំនួន ១.៥០០ ដុល្លារ

៧ -លោក **ឈុន ឈិន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១.១៨៥ ដុល្លារ

៨ -ឧបាសិកា **ហ៊ាង ចាង** ហៅលោកយាយ **ពិ សុណា** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១.៣១០ ដុល្លារ

៩ -ឧបាសិកា **ហ៊ុន តិសៀវ** សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ១.២៣៤ ដុល្លារ

១០ -លោក **ទា អៀមហ៊ួរ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ចំនួន០៣ខ្នង ធ្វើរបងថ្មមុខវិទ្យាល័យ និងមុខសាលាបឋមសិក្សាជ័យឧត្តម នៅវិទ្យាល័យភ្នំស្រុក ឃុំស្រះជីក ស្រុកភ្នំស្រុក និងនៅសាលាបឋមសិក្សាបត់ត្រង់ ឃុំបត់ត្រង់ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក	**នោ ខួត**	និងលោកស្រី **យិន ទុំ**	ថវិកា ចំនួន ១១.០០០ ដុល្លារ
២-លោក	**នោ ម៉ាន់**	និងលោកស្រី **ឃួន វណ្ណា**	ថវិកា ចំនួន ១០.៥០០ ដុល្លារ
៣-លោក	**ឡៅ ប៊ុនធឿន**	និងលោកស្រី **សំ ម៉ាន់ឌី**	ថវិកា ចំនួន ១០.២០០ ដុល្លារ
៤-លោក	**គង់ មាន**		ថវិកា ចំនួន ១៤.៣៩០ ដុល្លារ
៥-លោកស្រី	**អៀង យ៉ាត**		ថវិកា ចំនួន ១៣.៧០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៖

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៤៣...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានជួយកសាងសាលារៀន និងសមិទ្ធផលមួយចំនួនទៀត នៅវត្តអង្គស្នាត ក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ចក់ ឌូ**	ចៅអធិការ វត្តអង្គស្នាត	បច្ច័យចំនួន ១៣.០៥០ ដុល្លារ
២-លោក	**ឡាក់ រ៉ី**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកា ចំនួន ២១.២០០ ដុល្លារ
៣-លោក	**រ៉ុន រ៉ឹម**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកា ចំនួន ១៤.២០០ ដុល្លារ

